ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
អគ្គនាយកដ្ឋានការងារ
នាយកដ្ឋានអធិការកិច្ចការងារ
លេខៈ ១៥៤/២២ ក.ប/អ.ក/អ.ធ.ក.

# លិខិតដាក់កំហិត

## ជម្រាបមក

## លោក លោកស្រី ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ស្ថិតក្រៅផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

**កម្មវត្ថុ** ៖ ការដាក់កំហិតស្តីពីការអនុវត្តបែបបទស្តីពីសហគ្រាស លក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ លក្ខខណ្ឌនៃបេឡាជាតិសន្តិសុខសង្គម និងលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ។

**យោង** ៖ -ច្បាប់ស្តីពីការងារ

-ប្រកាសលេខ៣៥៨/២១ ក.ប/ប្រ.ក.អ.ធ.ក. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

-សេចក្តីជូនដំណឹងលេខ ០២២/២២ ក.ប/ស.ជ.ណ.អ.ធ.ក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ស្តីពីការអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូម **លោក លោកស្រី** មេត្តាអនុវត្តឱ្យបានរួចស្រេចអំពីបែបបទស្តីពីសហគ្រាស និងឱ្យបានត្រឹមត្រូវតាមច្បាប់នូវលក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ លក្ខខណ្ឌនៃបេឡាជាតិសន្តិសុខសង្គម និងលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ ខាងក្រោមចាប់ពីពេលនេះតទៅ៖

**ក.បែបបទស្តីពីសហគ្រាស**

១-ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

**ខ.លក្ខខណ្ឌទូទៅនៃការងារ**

១-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់ឈ្នួលថ្ងៃបុណ្យនិងប្រាក់បំណាច់ធ្វើការថ្ងៃឈប់សម្រាកបុណ្យជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

២-ត្រូវផ្តល់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៣-ត្រូវផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាមានថិរវេលាកំណត់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៤-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការនៅពេលយប់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៥-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៦-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងនៅពេលយប់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៧-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសថិរវេលាកំណត់



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៨-ត្រូវមានលិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោងពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសចិរវេលាដែលបានអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

-ត្រូវមានលិខិតអនុញ្ញាតធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការនៅថ្ងៃបុណ្យលើសពីការអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

៩-ត្រូវមានលិខិតអនុញ្ញាតព្យួរការឈប់ការសម្រាកប្រចាំសប្ដាហ៍ពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសចិរវេលាដែលបានអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

១០-មិនត្រូវមានការរើសអើងពេលជ្រើសរើសកម្មករនិយោជិតចូលធ្វើការ

១១-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការងារដោយបង្ខំ

១២-ត្រូវផ្ដល់រយៈពេលនៃការឈប់សម្រាកលំហែមាតុភាពឱ្យបានត្រឹមត្រូវ

-ត្រូវផ្ដល់ប្រាក់ឈ្នួលគិតទាំងប្រាក់បន្ទាប់បន្សំនៅពេលឈប់សម្រាកលំហែមាតុភាពឱ្យបានត្រឹមត្រូវ

១៣-មិនត្រូវបញ្ឈប់កម្មករនិយោជិតជាស្ត្រីដែលមានផ្ទៃពោះ ឬឈប់សម្រាលកូន ឬបង្ខំឱ្យលាឈប់ពីការងារ

១៤-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ក្មេងដែលមានអាយុក្រោម១៨ឆ្នាំឱ្យបានត្រឹមត្រូវ

-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬប្រភេទការងារ និងមុខរបរដែលប៉ះពាល់ដល់សុខភាព សន្តិសុខការងារ ឬសីលធម៌របស់ក្មេង

-មិនត្រូវឱ្យក្មេងអាយុចាប់ពី១៥ឆ្នាំដល់តិចជាង១៨ឆ្នាំធ្វើការនូវប្រភេទការងារប្រកបដោយគ្រោះថ្នាក់

-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់

-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់ក្នុង១សប្ដាហ៍

-ត្រូវឱ្យកម្មករនិយោជិតវ័យក្មេងឈប់សម្រាកប្រចាំសប្ដាហ៍ឱ្យបានត្រឹមត្រូវ

១៥-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសប្រចាំឆ្នាំ

១៦-ត្រូវរៀបចំប័ណ្ណការងារនិងសៀវភៅការងារជូនកម្មករនិយោជិតខ្មែរឱ្យបានត្រឹមត្រូវ

**គ.លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ**

១-ត្រូវរៀបចំទីតាំងដាក់កាកសំណល់ធម្មតាឱ្យបានត្រឹមត្រូវ

២-ត្រូវរៀបចំទីតាំងស្តុកទុកកាកសំណល់សារធាតុគីមី ឬសារធាតុពុល នៅដាច់ដោយឡែក និងមានសុវត្ថិភាព

៣-ត្រូវរៀបចំប្រអប់សង្គ្រោះប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

៤-ត្រូវរៀបចំបន្ទប់រុំរបួសប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

៥-ត្រូវអនុវត្តនូវវិធានសុវត្ថិភាពការងារឱ្យបានត្រឹមត្រូវ ដើម្បីបង្ការគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ

៦-ត្រូវរៀបចំប្រព័ន្ធបញ្ចេញ បញ្ចូលខ្យល់នៅក្នុងអគារឱ្យសមស្របតាមបទដ្ឋានដែលបានកំណត់

៧-ត្រូវរៀបចំច្រកគ្រោះអាសន្នទាំងអស់អាចចេញដោយសុវត្ថិភាព មានភាពធំទូលាយ គ្មានអ្វីមកបាំង និងមិនចាក់សោរ

៨-ត្រូវបិទសញ្ញាការសុវត្ថិភាពនិងសុខភាពការងារឱ្យបានគ្រប់គ្រាន់នៅតាមប៉ុស្តិ៍ការងារ និងនៅតាមទីតាំងផ្សេង

៩-ត្រូវរៀបចំឡចំហាយ និងអនុវត្តការប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេសនិងសុវត្ថិភាពការងារ

១០-ត្រូវប្រើប្រាស់គ្រឿងម៉ាស៊ីន ឬគ្រឿងយន្តឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេស និងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ

**ឃ.លក្ខខណ្ឌនៃរបបសន្តិសុខសង្គម**

១-ត្រូវរៀបចំចុះបញ្ជិការោងចក្រ សហគ្រាសនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

២-ត្រូវរៀបចំចុះបញ្ជិកាកម្មករនិយោជិតនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

៣-ត្រូវបង់ភាគទានឱ្យកម្មករនិយោជិតផ្អែកហានិភ័យការងារ និងផ្អែកថែទាំសុខភាពឱ្យបានត្រឹមត្រូវ

**ង.លក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ**

១-ត្រូវរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

-ត្រូវអនុវត្តតាមប្រកាសស្តីពីប្រតិភូបុគ្គលិកនៅក្នុងរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

**លោក លោកស្រី** ត្រូវអនុវត្តឱ្យខានតែបានតាមលិខិតដាក់កំហិតនេះ ក្នុងករណីល្មើសនឹងចំណុចអាទិភាពណាមួយនឹងត្រូវទទួលរងការផាកពិន័យភ្លាមៗពីអធិការការងារយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ **លោក លោកស្រី** ត្រូវអនុវត្តតាមការដាក់កំហិតឱ្យបានត្រឹមត្រូវតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សូម **លោក លោកស្រី** ទទួលនូវសេចក្តីរាប់អានពីខ្ញុំ។

ថ្ងៃ ស្ង៉ែ ១២កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០២២

**អធិការការងារ**

**និងជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ខេម ប៊ុនឈាន**